ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

&&&*&&&

សាលាដំបូងខេត្តកំពត

&&*&&

សាលក្រមព្រហ្មទណ្ឌលេខ: ២៩៤

ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧

សំណុំរឿងព្រហ្មទណ្ឌលេខ: ២៥៦

ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្ត កំពត

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្ត កំពត។

- កាលបរិច្ឆេទបើកសវនាការ: នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ រសៀល។
- កាលបរិច្ឆេទប្រកាសសាលក្រម: នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧ រសៀល។

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] សមាជិកក្រុមប្រឹក្សា

លោកស្រី [redacted] សមាជិកក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ២៥៦ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៧ ដែលមានជនជាប់ចោទ:

១. ឈ្មោះ[redacted] រី ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃកែស ឃុំតំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅ[redacted]កំពត។ ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (គេចខ្លួន)

២. ឈ្មោះ [redacted]ទីន ភេទប្រុស អាយុ៣៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិធ្នង់ ឃុំឫស្សីស្រុក ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅនៅភូមិ[redacted]ខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted]" មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (ក្នុងឃុំបទល្មើសផ្សេង)

៣. ឈ្មោះ [redacted] អួន ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្រពាំងបី ឃុំល្បើក ស្រុកឈូក ខេត្តកំពត។ ទីលំនៅនៅភូមិ[redacted] ស្រុកកំពង់ ត្រាច

Scanned by CamScanner

ខេត្តកំពត។ ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted]រ" មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (គេចខ្លួន)

ត្រូវបានជាប់ចោទពីបទៈ ប្លន់ ប្រព្រឹត្តនៅភូមិឈើទាល ឃុំជីពូវ័ន្ត ស្រុកជុំគីរី ខេត្តកំពត កាលពីថ្ងៃទី ០៣.០៥.២០០៧ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែងក្នុង មាត្រា ៦ នៃច្បាប់ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទខាងលើ។

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៣០៨ ចុះថ្ងៃទី ១២.០៥.២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត។

## ដើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] ភេទប្រុស អាយុ៤៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅនៅភូមិឈើទាល ឃុំជីពូវ័ន្ត ស្រុកជុំគីរី ខេត្តកំពត។

## ឯអង្គហេតុនៃរឿងមានដូចតទៅៈ

កាលពីថ្ងៃទី ០៣.០៥.២០០៧ មានករណីលួចក្របីស្ទាវ ០១ក្បាល កើតឡើងនៅភូមិឈើទាល ឃុំជីពូវ័ន្ត ស្រុកជុំគីរី ខេត្តកំពត ដែលបង្កដោយឈ្មោះ [redacted] រិ, [redacted] ចឺន និង[redacted] អូន បាននាំគ្នាលួចក្របីស្ទាវ ០១ក្បាល ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ដៃ។ លុះដល់ថ្ងៃទី ០៨.០៥.២០០៧ ពួកគេបានដឹកក្របីមកដល់ចំណុចភូមិល្អាង ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត ពេលឃើញសមត្ថកិច្ច ពួកគេក៏រត់គេចខ្លួនដោយទុកក្របីចោលនៅទីនោះ ហើយសមត្ថកិច្ចបានយកមកប្រគល់ឱ្យម្ចាស់ដើមវិញ។

## នាពេលសវនាការ

**ក្រោយពីបានៈ**

- ស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ចឺន
- ស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ឈិន
- ស្តាប់ចម្លើយរបស់សមត្ថកិច្ចឈ្មោះ [redacted] វឿន
- ស្តាប់អំណានម្លើយជនរងគ្រោះឈ្មោះ [redacted] ដៃ
- ស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted] ប្រុស
- ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ស្តាប់ការកត់សម្គាល់ខ្លីៗ និងជាសំណូមពរចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

Scanned by CamScanner

## <u>សំអាងហេតុ</u>

១-តាមចម្លើយរបស់ជនរងគ្រោះ និងរបាយការណ៍សន្និដ្ឋានដោយមន្ត្រីនគរបាលយុត្តិធម៌ឃើញថា ពិតជាមានអំពើ ប្លន់យកក្របី កាលពីថ្ងៃទី ០៣.០៥.២០០៧ ដែលប្រព្រឹត្តដោយជនល្មើសឈ្មោះ [redacted] រិ, [redacted] ចឺន និង [redacted]អួន ទៅលើជនរងគ្រោះឈ្មោះ [redacted]ផៃ ប្រាកដមែន។

២-ជនជាប់ចោទបានរត់គេចខ្លួនចាប់តាំងតែពីថ្ងៃដែលខ្លួនបានប្រព្រឹត្តបទល្មើសមកម្លេះ។

*ការរត់គេចខ្លួនរបស់ជនជាប់ចោទ អាចសបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ហើយរត់គេចខ្លួនពីទំនួលខុសត្រូវ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ចឺន ត្រូវបានជាប់ពន្ធនាគារនៅក្នុងបទល្មើសផ្សេង។*

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ផៃ បានអះអាងថា ខ្លួនពិតជាបានបាត់ក្របីឈ្មោលមួយក្បាលកាលពីថ្ងៃទី ០៨.០៥.២០០៧ ប្រាកដមែន។ ក្របីនោះខ្លួនលែងចោលតាំងពីព្រឹកច្រូតហើយ។ លុះដល់ថ្ងៃទី ០៨.០៥.២០០៧ ទើបខ្លួនដឹងថាបាត់ក្របី។ ខ្លួនមិនដឹងអ្នកដែលលួចក្របីខ្លួននោះទេ ហើយក៏គ្មានសង្ស័យទៅលើអ្នកណាដែរ។ លុះដល់ថ្ងៃទី២៤.០៥.២០០៧ ទើបខ្លួនដឹងដំណឹងពីលោកមេឃុំជម្ងវនថា នគរបាលឃុំល្អាង ស្រុកដងទង់ ចាប់បានក្របីមយយក្បាល។ ខ្លួនបានទៅប៉ុស្តិ៍ល្អាងឃើញក្របីនោះពិតជាក្របីរបស់ខ្លួនមែន ហើយនគរបាលបានប្រគល់ក្របីៈនោះឱ្យខ្លួនវិញ។

-ចម្លើយរបស់សាក្សីឈ្មោះ[redacted] ប្រុស នៅថ្ងៃខែមិនចាំ ឆ្នាំ ២០០៧ ម៉ោងប្រហែល ៤រសៀល ខ្លួនទៅមើលទឹកស្រែ បានឃើញក្របីឈ្មោលមួយក្បាលនៅក្បែព្រៃជិតស្រែរបស់ខ្លួន តែខ្លួនមិនដឹងថាក្របីឈ្មោលមួយក្បាលនោះជាក្របីរបស់អ្នកណាទេ។ បានប្រហែលជាពីរថ្ងៃក្រោយមកទើបសមត្ថកិច្ចដឹងហើយបានប្រគល់ក្របីនោះឱ្យម្ចាស់ដើមគេវិញហើយ។

-ឈ្មោះ [redacted]លិត បានឆ្លើយថា ខ្លួនបានឃើញមានមនុស្សម្នាក់ដឹកក្របីមួយ ហើយមានម្នាក់ទៀតគេចពីហ្វូងគោរបស់ខ្លួនទៅខាងកើតដើរឆ្លងអូរមានកាន់ខ្សែមួយចង្វាយ ខ្លួនមិនស្គាល់អ្នកដឹកនោះទេ ហើយពេលទៅដល់ផ្ទះមានចាស់ៗសួរពីរឿងបាត់ក្របីនោះទើបខ្លួនប្រាប់ពីអង្គហេតុ។ ខ្លួនមិនចាំមុខទេ គាត់ដឹកពីខាងលិចអូរឆ្លងអូរទៅ ខ្លួនឃើញពីចំងាយ។

-តាមការបំភ្លឺរបស់សមត្ថកិច្ចឈ្មោះ[redacted]រឿន បានឱ្យដឹងថា នៅថ្ងៃកើតហេតុនោះខ្លួនចង់ភ្លេចហើយវាយូរពេក។ ខ្លួនបានទទួលទូរស័ព្ទពីពលរដ្ឋថាមានគេដឹកក្របីដើរលក់ ប្រហែលមិនមែនជាម្ចាស់ក្របីទេ នៅម្តុំយាយម៉ៅ ខ្លួនក៏ទៅតាមមើល ហើយមានសាក្សីឃើញឈ្មោះ [redacted] ចឺន យកក្របីទៅចងនៅផ្ទះ ខ្លួនដើរតាមដានក្របីរហូតដល់បាត់ បានឃើញក្របីចងទុកចោលក្នុងផ្ទះទុកចោលមួយកន្លែង។

៤-លោកតំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ : ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ ចម្លើយរបស់ជនជាប់ចោទ ថាខ្លួនមិនបានដឹកក្របីគេនោះទេ គឺខ្លួននៅពោធិ៍សាត់។ តែតាមចម្លើយរបស់សមត្ថកិច្ច និងអំណានចម្លើយរបស់សាក្សី ឃើញថា មានគេឃើញ[redacted]ចឺន យកក្របីនោះទៅចង។ តាមអង្គហេតុ នៃការចោទប្រកាន់តាមមាត្រា ៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ លួចមានគ្នាច្រើន ជាបទប្លន់។ យោងតាមក្រមព្រហ្មទណ្ឌបទល្មើសដែលមានចែងក្នុងច្បាប់ថ្មីស្រាលជាង ដូច្នេះ

តំណាងអយ្យការសុំកែប្រែពីបទ លួច មានស្ថានទម្ងន់ទោស មកបទលួច តាមមាត្រា ៣៥៣វិញ។ ដូច្នេះសុំឱ្យក្រុមប្រឹក្សាសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។

-លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ : នៅក្នុងសំណុំរឿងនេះ តំណាងអយ្យការពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីចោទប្រកាន់កូនក្តីខ្លួន ពីបទលួចដោយមានស្ថានទម្ងន់ទោសនោះឡើយ ហើយក្នុងករណីនេះ ក៏ពុំមានធាតុផ្សំគ្រប់គ្រាន់ក្នុងការបង្កើតឱ្យបានជាបទល្មើសព្រហ្មទណ្ឌនោះដែរ។ ដោយឈរលើគោលការណ៍សច្ចាធារណ៍នៃទោស ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣៨ ដែលបានចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ខ្ញុំសូមសំណូមពរក្រុមប្រឹក្សាជំនុំជម្រះ មេត្តាសម្រេចឱ្យកូនក្តីខ្លួនបានរួចផុតពីការចោទប្រកាន់ ពីបទលួច ដោយមានស្ថានទម្ងន់ទោស។

៥-ជនជាប់ចោទជានីតិជន បានប្រព្រឹត្តសកម្មភាពខាងលើ ដោយចេតនា តែមិនបានយល់ដឹងគ្រប់គ្រាន់ពីអំពើរបស់ខ្លួននោះទេ។

៥.១-មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] រិ, [redacted] ចឺន និង [redacted] អូន ពីបទ ប្លន់ ប្រព្រឹតនៅភូមិ ឈើទាល ឃុំជិពូវន្ត ស្រុកជុំគីរី ខេត្តកំពត កាលពីថ្ងៃទី ០៣.០៥.២០០៧ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែងក្នុង មាត្រា ៦ នៃច្បាប់ ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៥.២- *បើពិនិត្យមើលអំពីធាតុផ្សំនៃបទល្មើស ប្លន់ ដែលមានចែងក្នុង មាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ គឺនៅក្នុងធាតុផ្សំនៃបទល្មើសលួចដោយមានគ្នាច្រើន ត្រូវបានចោទប្រកាន់ជា បទប្លន់ តែដោយឡែក បទល្មើសលួច ដែលមានចែងក្នុងមាត្រា ៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ លុះណាតែមានការប្រើហឹង្សា ការលួចដោយមានគ្នាច្រើនវាពុំចូលក្នុងស្ថានទម្ងន់ទោសនោះទេ វាគ្រាន់តែជាបទល្មើសលួច ដែលមានចែងក្នុងមាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌ។*

*-បើយោងតាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាល ឬ ធ្ងន់ជាង ដូច្នេះ តុលាការគប្បីសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបីនាក់ តាមមាត្រា៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ។*

៥.៣-គប្បីប្រកាសទណ្ឌកម្មលើជនជាប់ចោទ កំណត់ម្នាក់ៗរយៈពេល ០២ឆ្នាំ(ពីរឆ្នាំ) ដោយពិចារណា ដល់ភាពធ្ងន់ស្រាលនៃសកម្មភាពល្មើស ផលប៉ះពាល់ និងព្យសនកម្ម ដែលកើតចេញពីអំពើល្មើស និងស្ថានភាព ផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ដូចខាងក្រោម:

-បទល្មើសដែលជនជាប់ចោទបានប្រព្រឹត្ត ធ្វើឱ្យជនរងគ្រោះបាត់បង់នូវទ្រព្យ ថ្វីត្បិតតែទ្រព្យនោះត្រូវបានជនរងគ្រោះទទួលយកវិញហើយ តែជនជាប់ចោទបានប្រព្រឹត្តិអំពើល្មើសដោយភាពក្លាហាន មិនមានភាពញញើតនោះទេ។ ម្យ៉ាង ទង្វើរបស់ជនជាប់ចោទបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុវត្ថិភាពភូមិឃុំ។ ស្ថានភាពទាំងអស់នេះហើយ ដែលជាហេតុនាំឱ្យតុលាការ ប្រកាសទោសដល់ជនជាប់ចោទ ដូចក្នុងចំណុច (៥.៣) ខាងលើ។

៦- ជនជាប់ចោទ ត្រូវបានតុលាការសម្រេចផ្តន្ទាទោសកំណត់ម្នាក់ៗចំនួន ០២ ឆ្នាំ (ពីរឆ្នាំ) ដោយគ្មានការព្យួរទោស ហើយជននេះមិនបានចូលខ្លួនមកបំភ្លឺនាពេលសវនាការ តាមការបង្គាប់បញ្ជារបស់តុលាការនោះទេ និងមានភស្តុតាងគ្រប់គ្រាន់ ច្បាស់លាស់ថាជននេះពិតជាបានប្រព្រឹត្តបទល្មើសខាងលើ។ ហេតុនេះ គប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជននេះ និងយកមកឃុំខ្លួនក្នុងពន្ធនាគារតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

៧-ជនរងគ្រោះឈ្មោះ [redacted] ផៃ មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងនោះទេ។ ដូច្នេះតុលាការ មិនពិចារណាដល់បញ្ហាសំណងនោះទេ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

**១-ផ្តន្ទាទោសជនជាប់ចោទ :**

ក. ឈ្មោះ [redacted]រិ ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃកែស ឃុំតំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅនៅ[redacted] ស្រុកទឹកឈូ ខេត្តកំពត។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted]រ" មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (គេចខ្លួន)

ខ. ឈ្មោះ [redacted]ថឺន ភេទប្រុស អាយុ៣៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិធ្នង់ ឃុំឫស្សីស្រុក ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅនៅភូ[redacted]កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត។ ឪពុកឈ្មោះ [redacted]រ" ម្តាយឈ្មោះ[redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (ក្នុងឃុំបទល្មើសផ្សេង)

គ. ឈ្មោះ[redacted] អួន ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្រពាំងបី ឃុំល្បើក ស្រុកឈូក ខេត្តកំពត។ ទីលំនៅនៅ[redacted] ស្រុកកំពង់ត្រាច ខេត្តកំពត។ ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ[redacted]"ស" ប្រពន្ធឈ្មោះ ច[redacted]"រ" មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (គេចខ្លួន)

**ដាក់ពន្ធនាគារកំណត់ម្នាក់ៗចំនួន ២ឆ្នាំ (ពីរឆ្នាំ) ពីបទ លួច។**

ប្រព្រឹត្តនៅភូមិឈើទាល ឃុំជំពូវន្ត ស្រុកជុំគិរី ខេត្តកំពត កាលពីថ្ងៃទី ០៣.០៥.២០០៧ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែងក្នុង មាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២-ឱ្យចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រិ និង[redacted]អួន ដែលមានសវតាជាតិខាងលើ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ថឺន កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រិ និង [redacted] អួន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ផៃ។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

Scanned by CamScanner

៦- ជនជាប់ចោទ ត្រូវបានតុលាការសម្រេចផ្តន្ទាទោសកំណត់ម្នាក់ៗចំនួន ០២ ឆ្នាំ (ពីរឆ្នាំ) ដោយឥតមានការព្យួរទោស ហើយជននេះមិនបានចូលខ្លួនមកបំភ្លឺនាពេលសវនាការ តាមការបង្គាប់បញ្ជារបស់តុលាការនោះទេ និងមានភស្តុតាងគ្រប់គ្រាន់ ច្បាស់លាស់ថាជននេះពិតជាបានប្រព្រឹត្តបទល្មើសខាងលើ។ ហេតុនេះ គប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជននេះ និងយកមកឃុំខ្លួនក្នុងពន្ធនាគារតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

៧-ជនរងគ្រោះឈ្មោះ [redacted] ផៃ មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងនោះទេ។ ដូច្នេះតុលាការ មិនពិចារណាដល់បញ្ហាសំណងនោះទេ។

## <u>ហេតុដូច្នេះ ទិនិច្ឆ័យសេចក្តី</u>

**១-ផ្តន្ទាទោសជនជាប់ចោទ :**

[redacted] ឈ្មោះ [redacted] រិ ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃកែស ឃុំតំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅនៅ [redacted] ស្រុកទឹកឈូ ខេត្តកំពត។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោ [redacted] "រ" មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (គេចខ្លួន)

ឈ្មោះ [redacted] ចឺន ភេទប្រុស អាយុ៣៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិធ្នង់ ឃុំឫស្សីស្រុក ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅនៅ [redacted] ង ស្រុកកំពង់ត្រាច ខេត្តកំពត។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (ក្នុងឃុំបទល្មើសផ្សេង)

គ. ឈ្មោ [redacted] អួន ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្រពាំងបី ឃុំល្បើក ស្រុកឈូក ខេត្តកំពត។ ទីលំនៅនៅភូមិព្រៃ [redacted] ក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត។ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] ន់ "ស" ប្រពន្ធឈ្មោះ [redacted] " មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (គេចខ្លួន)

**ដាក់ពន្ធនាគារកំណត់ម្នាក់ៗចំនួន ២ឆ្នាំ (ពីរឆ្នាំ) ពីបទ លួច។**

ប្រព្រឹត្តនៅភូមិឈើទាល ឃុំជំពូវន្ត ស្រុកជុំគីរី ខេត្តកំពត កាលពីថ្ងៃទី ០៣.០៥.២០០៧ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែងក្នុង មាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២-ឱ្យចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រិ និង [redacted] អួន ដែលមានសវតាជាតិខាងលើ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចឺន កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រិ និង [redacted] អួន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផៃ។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

[redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

Scanned by CamScanner